# ការសំភាសន៍របស់លោកយាយ តេង មុំ

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ តេង មុំ

<u>ការសង្ខេបប្រវត្តិរបស់ លោកយាយ តេង មុំ</u>

លោកយាយ តេង មុំ មានអាយុ76ឆ្នាំ នៅក្នុងឆ្នាំ2018 លោកយាយ តេង មុំ មានភេទស្រី លោកយាយ តេង មុំ មានទីលំនៅបច្ចុប្បន្ននៅ ភូមិទួល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

កៈ
ចឹងជាដំបូងខ្ញុំអរគុណយាយដែរបានអោយខ្ញុំពិភាក្សាជាមួយយាយដែរទាក់ទងពីប្រវត្តិរបស់យាយ
ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ
ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗៗអោយពួកគាត់
បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង
ប្រវត្តិរបស់ជួនយាយចឹងនៅពេលដែរខ្ញុំបានសំភាសន៍យាយ
ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយយាយ ចឹងដោយសារតែវេបសាយដែរមានឈ្មោះថា
www.cambodianoralhistories.byu.edu
ចឹងសំរាប់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ដែរបានពិភាក្សាជាមួយតាទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេយាយ?

ខៈ អត់អីទេបើសិនជាចង់សំភាសន៍ សំភាសន៍ទៅមានទាស់ខុសអី

កៈ បាទយាយបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍យាយខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍យាយគឺនៅថ្ងៃទី10ខែ4 ឆ្នាំ2018 ហើយឡើងនៅភូមិទួល

ខៈ នៅភូមិទួល

កៈ នៅភូមិទួល ឃុំមហាសាង ស្រុកអី?

ខៈ នៅស្រុកភ្នំស្រួច

កៈ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ?

ខៈ នៅខេត្តកំពង់ស្ពឺ

កៈ សំរាប់យាយមានឈ្មោះពេញនឹងឈ្មោះអីគេដែរទៅយាយ?

ខៈ ខ្ញុំមានឈ្មោះយាយ មុំ

កៈ អើរឈ្មោះទាំងអស់ហាសយាយ?

ខៈ ឈ្មោះទាំងត្រកូលនឹងហោសឈ្មោះតេង មុំ

កៈ យាយមានឈ្មោះតេង មុំ ចុះមានឈ្មោះហៅក្រៅអត់យាយ?

ខៈ អត់មានទេហៅតែឈ្មោះចឹងតែម្ដងនឹងមានឈ្មោះតែយាយមុំៗៗចឹងតែម្ដងនឹង

កៈ ចុះកាលពីក្មេងនឹងធ្លាប់មាននរណាហៅឈ្មោះយាយអីផ្សេងដែរទេយាយ?

ខៈ អត់អត់មានទេនឹង

កៈ ចឹងអត់មានទេហោសយាយ?

ខៈ អត់ដែរមានទេ

កៈ ចុះសព្វថ្ងៃយាយអាយុប៉ុន្មានដែរយាយ?

ខៈ ឥឡូវនឹងខ្ញុំអាយុ76ឆ្នាំហើយនឹង

កៈ អ៎ូ!!យាយអាយុ76ឆ្នាំ ចុះយាយកើតនៅថ្ងៃខែឆ្នាំណាយាយមានចងចាំទេ?

ខៈ អ៎ូ!!សម័យនឹងម៉ែឪអត់មានទុកសំភាសន៍ដូចសម័យឥឡូវនឹងទេ ខ្ញុំអត់ៀដឹងដែរនឹង

កៈ បាទៗៗបង ចឹងយាយកើតនៅឆ្នាំ1942

ខៈ ចា៎!!នឹងហោស

កៈ ចឹងសំរាប់យាយឆ្នាំច័ន្ទគតិហាសយាយកើតនៅឆ្នាំអីគេដែរយាយ លក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសយាយ?

ខៈ ខ្ញុំកើតនៅឆ្នាំរកា

កៈ ចឹងយាយកើតនៅឆ្នាំរកាណាយាយ?

ខៈ នឹងហើយចឹង

កៈ ចុះយាយកើតនៅណាដែរយាយ?

ខៈ ខ្ញុំកើតនៅនឹងតែម្តងនឹង

កៈ កើតនៅភូមិទួល

ខៈ កើតនៅនឹងតែម្តងនឹង ចាស់បុរាណគេហៅភូមិត្រាចក្រទេ

កៈ អូ៎!!គេហៅភូមិត្រាចក្រហោសបង?

ខៈ ចា៎!!តែដល់ពេលឥឡូវនឹងគេហៅភូមិទួលវិញ

កៈ ចឹងនៅភូមិទួល ឃុំមហាសាង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺណា?

ខៈ នឹងហើយនៅខេត្តកំពង់ស្ពឺ

កៈ ចឹងសំរាប់យាយមានបងប្អូនបង្កើតនឹងប៉ុន្មាននាក់ដែរយាយ?

ខៈ បងប្អូនបង្កើតរបស់ខ្ញុំនឹងមាន7នាក់ប៉ុន្តែបានស្លាប់អស់ហើយនឹង

កៈ អូ៎!!ចឹងនៅសល់តែយាយមួយទេហោសយាយ?

ខៈ អត់ទេនៅសល់2នាក់ដែរ

កៈ ចឹងនៅសល់2នាក់?

ខៈ ចាប់មកនៅសល់2នាក់នឹង

កៈ ចុះយាយជាកូនទីប៉ុន្មានដែរយាយ?

ខៈ ខ្ញុំមានកូនតែម្នាក់នឹងហាស

កៈ អត់ទេបងប្អូនរបស់យាយយាយជាកូនទីប៉ុន្មាន?

ខៈ ចង់សួរយាយឯងជាកូណទីប៉ុន្មានទី2រឺមួយក៏ទី3ដែរ ខ្ញុំជាកូនទី2នឹង

កៈ ចឹងយាយជាកូនទី2ណយាយ ចុះយាយមានស្រីប៉ុន្មាន
ហើយនឹងប្រុសប៉ុន្មានបងប្អូនរបស់យាយហាស?

ខៈ មានប្រុសតែពីរនាក់ទេនឹងហើយ

កៈ មានស្រី5នាក់ចឹងហោសយាយ?

ខៈ ស្រីមាន5នាក់នឹង

កៈ បងប្អូន7នាក់ហីបង?

ខៈ ចាំ!!បងប្អូន7នាក់នឹង

កៈ ចឹងមានន័យថានៅរស់តែ2នាក់ទេក្រៅពីនឹងស្លាប់អស់5នាក់?

ខៈ ឥឡូវនឹងហើយចឹង

កៈ ប៉ុន្តែដូចជាគាត់ស្លាប់នៅជំនាន់ពលពតរឺមួយយ៉ាងម៉េចដែរយាយ?

ខៈ អត់មានស្លាប់នៅពលពតទេ មកស្លាប់នៅស្រុកចឹងតែម្តងនឹងហាស
ស្លាប់នៅពលពតហើយនឹង ស្លាប់អស់2នាក់នឹង

កៈ អូ៎!!ចឹងហោសយាយ?

ខៈ មកជំនាន់ចេះទៀតនឹងស្លាប់អស់3នាក់នឹង

កៈ
អូ៎!!ចុះយាយមានចងចាំឈ្មោះបងប្អូនរបស់យាយនឹងមានឈ្មោះអីគេខ្លះដែរទៅយាយ?

ខៈ ខ្ញុំចងចាំដែរនឹង

កៈ ចុះមានឈ្មោះអីគេខ្លះដែរទៅយាយ?

ខៈ បងគេបង្អស់នឹងមានឈ្មោះតេង ចាន់

កៈ ចុះទី2នឹងមានឈ្មោះអីយាយ?

ខ៖  ទី2នឹងមានឈ្មោះតេង មុំ

ក៖  ទី2នឹងយាយហោស?
ខ៖  នឹងហើយខ្ញុំនឹងឯង

ក៖  ចុះទី3វិញយាយ?

ខ៖  ទី3នឹងមានឈ្មោះតេង សុំ

ក៖  ចុះទី4វិញយាយ?

ខ៖  ទី4នឹងមានឈ្មោះ តេង ចិន

ក៖  ចុះទី5វិយាយ?

ខ៖  ទី5នឹងមានឈ្មោះតេង សឿន

ក៖  ចុះទី6វិញយាយ?

ខ៖  ទី6នឹងមានឈ្មោះតេង ស៊ុ

ក៖  ចុះពៅគេវិញយាយ?

ខ៖  ពៅគេនឹងមានឈ្មោះតេង សៀក

ក៖  អ៎ូ!!ចុះអ្នកដែរនៅរស់នឹងកូនទីប៉ុន្មានខ្លះដែរទៅយាយ
នៅយាយមួយទី2នឹងនៅទីប៉ុន្មានមួយទៀត?

ខ៖  នៅតែទី4នឹង

ក៖  អ៎ូ!!នៅទី4ហោសយាយ?

ខ៖  នឹងហើយ

ក៖
ចុះយាយធ្លាប់មានចងចាំអនុស្សាវរីយ៍អីកាលពីយាយនៅក្មេងៗៗជាមួយបងប្អូនរបស់យាយដែរទេ ដូចលក្ខណៈថាឡើកបាយឡ នឹងលេងបិទពួនអីចឹងហាស?

ខ៖ អ៎ូ!!នៅជំនាន់ណុងគេលេងតែបាយឡឹកបាយឡទេនឹង លេងចូលឆ្នាំនឹងលេងអន្ទាក់នឹងលេងឆកក្អែកពងអីចឹងទៅ

ក៖ លេងអីគេវិញយាយ?

ខ៖ លេងឆកក្អែកពង
លេងបែបចាស់ពីដើមហាសយើងមិនដែរស្គាល់ទេល្បែងប្រជាប្រិយ៍ហាស

ក៖ អ៎ូ!!មួយនឹងសប្បាយហោសបង?

ខ៖ សប្បាយហើយនឹងគេហៅទាញស្អីគេទេជួរ ទាញគួចអណ្តើក

ក៖ អ៎ូ!!ទាញគួចអណ្តើក?

ខ៖ ទាញជួរយើងដាក់ក្រម៉ាចេះនឹងហាស

ក៖ អ៎ូ!!គេលេងទាញជាប់សសរនឹងហោសបង?

ខ៖
អត់ទេគេចាប់ទាញដាក់ក្រម៉ាអន្ទាក់ចឹងទៅវារទៅចឹងទៅណាស់យើងប្រឹងទាញចឹងទៅណាស់

ក៖ អ៎ូ!!អានឹងសប្បាយហាសណាបង?

ខ៖ សប្បាយប៉ុន្តែយើងភ្លេចអស់ហើយក្មេងសម័យឥឡូវនឹង
ហើយដល់ចឹងអាក្មេីយមួយចឹងតែម្តងនឹងទាញប្រុស ស្រីតែម្តងនឹង

ក៖ បាទ!!ប៉ុន្តែបងទាន់ណាបង?

ខ៖ ខ្ញុំទាន់ទាញអណ្តើក ប៉ុន្តែឆកពងក្អែកនឹងខ្ញុំអត់ទាន់ទេចូលអស់ហើយនឹង

ក៖ ចុះដូចជាបងឥឡូវនឹងបងអាយុប៉ុន្មានដែរបង?

ខ៖ ខ្ញុំហោសខ្ញុំទើបតែអាយុ28ឆ្នាំទេ
តែខ្ញុំកើតមកនឹងខ្ញុំអត់លេងទេប៉ុន្តែខ្ញុំនៅតូចខ្ញុំចងចាំបានឃើញចាស់ៗគេលេងនឹង

ក៖ ប៉ុន្តែនៅក្នុងភូមិនឹងគេលេងហោសបង?

ខ៖ ចាំ!!ចាស់ៗៗដូចថាកូនបីបួនចឹងទៅវាឈរមើលគេលេងនឹង

ក៖ អ្ហ៎!!សប្បាយហើយចឹងយាយ?

ខ៖ អត់ទាន់ទេតូច ត្រឹមម៉ោងណោះ

ក៖ អ្ហ៎!!លេងទាល់តែយប់ហោសបង?

ខ៖ លេងសប្បាយណាស់លេងយប់ខែភ្លឺ

ក៖ ប៉ុន្តែនៅភូមិនឹងឥឡូវនឹងគេមានលេងទៀតអត់?

ខ៖ អត់មានទេស្ងាត់ឥឡូវនឹងគេប្រើតែទូរស័ព្ទ

ក៖ ចូលឆ្នាំក៏គេអត់លេងដែរនឹង?

ខ៖ អត់ទេគេប្រើតែទូរស័ព្ទ

ក៖ អ្ហ៎!!យ៉ាប់ដែរចឹង?

ខ៖ ចឹងទូរស័ព្ទសប្បាយតែភ្នែកម្នាក់ៗៗទេ

ក៖ បាទ!!ចឹងគេចង់លេងជុំគ្នាអត់មានទេ?

ខ៖ អត់មិនមែនដូចយើងទេអត់កើតល្បែងប្រជាប្រិយ៍នឹងស្ងាត់ណាស់
ចូលឆ្នាំដូចអត់ចូលឆ្នាំចឹង

ក៖ បាទបងបាទ
ចុះយាយគិតថាកាលពីនៅក្មេងនឹងតើយាយចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់
យាយដែរនឹងហាសដែរយាយចូលចិត្តលេងហាស?

ខ៖ លេងនឹងទៅពួនលេងអីនៅតូចៗៗចឹងទៅលេង
លេងទៅពួនលេងអាស្វាដណ្ដើមគ្នាចឹងទៅ

ក៖ អ្ហ៎!!លេងស្វាដណ្ដើមទី?

ខ៖ មានសសរចឹងទៅផ្លាស់គ្នាចឹងទៅស្វាដណ្ដើមគ្នានឹង

កៈ អូ!!ស្វាដណ្ដើមទីហៅយាយ
យាយហៅស្វាដណ្ដើមគ្នាខ្ញុំអត់ដឹងខ្ញុំលឺតែហៅស្វាដណ្ដើមគ្នា?

ខៈ នឹងហើយស្វាដណ្ដើមគ្នានឹងហាស

កៈ អត់អីទេយាយល្អសប្បាយយាយ
ប៉ុន្តែដូចជាប្អូនរបស់យាយនឹងសព្វថ្ងៃគាត់នៅណាដែរទៅ?

ខៈ នៅមួយនោះនឹងនៅខាងលិចនឹង

កៈ ដូចជាគាត់ធ្វើអីគេដែរឥឡូវនឹងយាយ?

ខៈ ប្ដីរបស់គាត់នឹងហោស?

កៈ អត់ទេដូចថាប្អូនរបស់យាយហាសគាត់នៅម្ដុំណុងគាត់ធ្វើអីគេដែរយាយ?

ខៈ គាត់អត់មានធ្វើអីគេទេ

កៈ ចុះគាត់មានកូនចៅដែរហើយាយ?

ខៈ មាន មានកូនមួយនឹង

កៈ កូនចៅរបស់របស់គាត់នៅចិញ្ចឹមគាត់ដែរហោសយាយ?

ខៈ កូនៗៗជាអ្នកចិញ្ចឹម

កៈ កូនហោសគាត់មែនប្អូនរបស់យាយហាស?

ខៈ ប្អូនរបស់គាត់អ្នកដែរមានកូនមួយដែរចេញធ្វើការងារនឹង

កៈ អូ!!បាទចឹងហោសបង?

ខៈ ចាំ!!ការងារតិចតួចនឹងប្រាក់ខែតិចតួចនឹងហាស

កៈ អូ!!ចឹងហោសបង ចុះសំរាប់ឪពុករបស់យាយនឹងមានឈ្មោះអីគេដែរយាយ?

ខៈ ឪពុករបស់ខ្ញុំនឹងមានឈ្មោះតា លឹម

កៈ មានឈ្មោះតា លឹម ចុះត្រកូលអីគេដែរយាយ?

ខ៖  ត្រកូលតានឹងហាស

ក៖  ឈ្មោះត្រកូលឈ្មោះតា អត់អីទេយាយ?

ខ៖  ត្រកូលមានឈ្មោះតា

ក៖  អូ៎!!ភ្លេចៗៗអត់អីទេយាយ ចុះសំរាប់តារបស់យាយ
ឪពុករបស់យាយនឹងគាត់កើតនៅណាដែរយាយ?

ខ៖  គាត់កើតនៅនេះកើតនៅភូមិស្លែងយើងនេះ
នៅឃុំមហាសាងយើងនឹងអមថ្មល់យើងនឹង ស្រុកទេសគាត់នៅនឹង

ក៖  បាទខ្ញុំស្តាប់មិនសូវបានទេ?

ខ៖  នៅភូមិស្លែងនេះ

ក៖  អូ៎!!នៅភូមិស្លែងយើងនឹងហោសបង?

ខ៖  ចា៎!!នៅភូមិស្លែងនឹងហាស

ក៖  បាទ ចុះសំរាប់ម្តាយរបស់យាយនឹងមានឈ្មោះអីគេដែរយាយ?

ខ៖  ម្តាយរបស់ខ្ញុំនឹងមានឈ្មោះយាយ ដឹប

ក៖  គាត់មានឈ្មោះយាយ ដឹប ចុះគាត់កើតនៅណាដែរយាយ?

ខ៖  គាត់កើតនៅនឹងដែរនឹង

ក៖  គាត់កើតនៅនឹងហោសយាយ?

ខ៖  គាត់កើតនៅនឹងអីនឹង

ក៖  ចុះសំរាប់ដូចជា
សំរាប់ឪពុករបស់យាយនឹងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិត
ដែរហោសយាយ?

ខ៖  ឪពុករបស់ខ្ញុំហោសអត់ដែរបានចិញ្ចឹមសត្វអីទេ គាត់ចិញ្ចឹមកូនគាត់ធ្វើ

ក៖  អត់ទេចង់និយាយថា?

ខ៖ គោគាត់មានពីរបីហោស កាត់អត់មានធ្វើការងារអីទេ
គាត់មើលតែគោធ្វើតែស្រែនឹងចៅ

ក៖ អូ៎!!ចឹងហោសយាយ?

ខ៖ នឹងហើយបើតាវិញអាចារ្យវត្ត

ក៖ យាយថាដាំព្រលិតយ៉ាងម៉េចខ្ញុំស្ដាប់អត់សូវបាន?

ខ៖ ដាំបន្លែនឹងហាស

ក៖ អូ៎!!ចឹងទេហោសបង?

ខ៖ ដាំបន្លែអីចឹងទៅនឹងដីគាត់ដាំចឹងមានឪឡឹកអីចឹង

ក៖ អូ៎!!ចឹងហោស?

ខ៖ នឹងហើយដាំអស់នឹងចឹង

ក៖ ខ្ញុំលឺតែទៅដាំព្រលិតខ្ញុំអត់ដឹងអីគេដែរ?

ខ៖ ទៅចេញព្រលិត ចាំខ្ញុំជាអ្នកបកប្រែ

ក៖ ចឹងបងជួយបកប្រែអោយខ្ញុំផងបង?

ខ៖ និយាយមកតែខុសទេចៅអើយខ្ញុំចាស់ហើយនឹង

ក៖ អត់ទេដោយសារតែយាយនិយាយមកខ្ញុំស្ដាប់មិនសូវបាននឹងហាស?

ខ៖ យាយអត់ធ្មេញទប់ពិបាកនិយាយណាស់

ក៖ បាទយាយ ចុះយាយឪពុករបស់យាយកាចរឺមួយក៏ស្លូតដែរយាយ?

ខ៖ អត់អីទេស្លូតទេនឹង

ក៖ ចឹងគាត់ស្លូតទេហោសយាយ
ចុះម្ដាយរបស់យាយនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរយាយ?

ខ៖ អើរគាត់ដប់តែប៉ុណ្ណឹងសំរាប់ចិញ្ចឹមជីវិត

កៈ  អូ!!គាត់ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ទាហោសយាយ?

ខៈ  នឹងហើយគាត់ចិញ្ចឹមជ្រូក គោ ពពែចឹងទៅនឹងគាត់ធ្វើស្រែនឹងហាស

កៈ  អូ!!កូនរបស់ភ្នាក់ហោស អូ ស្វាបដេកទៅវិញហើយនឹង
ចុះយាយមានដឹងថាម្ដាយរបស់យាយកាច រឺមួយក៏ស្លូតដែរ?

ខៈ  គាត់អត់កាចទេ

កៈ  ចឹងគាត់ស្លូតទេណយាយ?

ខៈ  គាត់ស្លូតទាំងអស់នឹងហាស

កៈ  ចឹងហោសយាយ?

ខៈ  អូ!!អត់ដែរទៅវៃកូនណាចៅណាទេនឹង

កៈ  ចុះយាយមានចងចាំអនុស្សាវរីយ៍អីជាមួយឪពុកម្ដាយរបស់យាយដែរទេ
ថាធ្លាប់បានធ្វើអីគេដែរចឹងហាសយាយ?

ខៈ  ថាម៉េចចឹងខ្ញុំស្ដាប់អត់បានទេ

កៈ  ចង់និយាយថាកន្លែងណាដែរយាយឯងមានសំខាន់ៗដែរបំភ្លេចមិនបាន
ជាមួយឪពុកម្ដាយនឹងហាសចឹង?

ខៈ  អត់ទេអត់មានទេចៅ

កៈ  អត់មានទេ អត់ទេចង់និយាយថាធ្លាប់បានធ្វើអីគេខ្លះចឹងហាស
ធ្លាប់មានកន្លែងកំសត់កំរអីជាមួយឪពុកម្ដាយចឹងហាស?

ខៈ  និយាយមកថាពីឆ្នាំ1979នឹងទៅកំសត់កំរនឹងចៅ

កៈ  ចឹងហោសយាយ?

ខៈ  រកតែស្លឹស៊ីហូបអត់បានទេនឹងហាស

កៈ  អូ!!ចឹងហោសយាយ
បាទចុះឪពុករបស់យាយនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅយាយដែរទេ?

ខ៖ សុំសួរម្តងទៀត

ក៖ ចង់និយាយថាឪពុករបស់យាយនឹងធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅយាយដែរទេ?

ខ៖ ប្រវត្តិកាលនៅក្មេងៗនឹង

ក៖ ប្រវត្តិកាលពីគាត់នៅរស់ នឹងនៅក្មេងៗនឹងហាស?

ខ៖ ធ្លាប់អត់និយាយថាគាត់នៅពីក្មេងយ៉ាងម៉េចចឹង

ក៖ ថាពីក្មេងនឹងគាត់យ៉ាងម៉េចចឹង?

ខ៖ នឹងហើយចឹង

ក៖ គាត់ធ្លាប់រកស៊ីអី?

ខ៖ កាលពីក្មេង

ក៖ នឹងសំរាប់ឪពុករបស់យាយហាស?

ខ៖ នឹងឪពុករបស់ខ្ញុំនឹងហាសអត់មានរកហូបរកអីទេ គាត់ធ្វើអាចារ្យវត្តិ ហើយនឹងអ្នកដេញវេលាការគេ

ក៖ អូ៎!!ចឹងហោសយាយ?

ខ៖ គាត់ធ្វើតែចឹងទេ

ក៖ បាទយាយបាទ ចុះម្តាយរបស់យាយធ្លាប់ប្រាប៉ពីប្រវត្តិទេ?

ខ៖ ម្តាយរបស់ខ្ញុំគាត់ចិញ្ចឹមជ្រូកចិញ្ចឹមអីចឹងទៅ

ក៖ អូ៎!!បាទចុះយាយតាខាងម្តាយរបស់យាយមានស្គាល់ឈ្មោះគាត់ទេ?

ខ៖ ថាម៉េចមិញ?

ក៖ យាយតាខាងម្តាយរបស់យាយទៀតហាស?

ខ៖ មានឈ្មោះយាយជ្រាប

ក៖ ឈ្មោះយាយជ្រាប ចុះតាវិញ?

ខ៖ តានឹងមានឈ្មោះតាសួន

ក៖ មានឈ្មោះតា សួន ហើយាយ ចុះយាយតាខាងឪពុកវិញ?

ខ៖ តាខាងឪពុកនឹង

ក៖ មានឈ្មោះតាគៀមហើយាយ?

ខ៖ អត់ទេមានឈ្មោះតាតេង នឹងតាបើយាយវិញមានឈ្មោះយាយម៉ម

ក៖ ចុះយាយតាខាងឪពុកគាត់កើតនៅណាដែរយាយមានដឹងទេ?

ខ៖ គាត់កើតនឹងគាត់កើតនៅខាងភូមិព្រៃស្ពុក

ក៖ នៅភូមិព្រៃស្ពុកហោសយាយ?

ខ៖ នៅអមថ្លែងនឹងនៅព្រៃស្ពុកនឹង

ក៖ ចុះយាយតាខាងម្ដាយ មិញយាយតាខាងឪពុកវិញ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះយាយតាខាងម្ដាយវិញគាត់កើតនៅណា?

ខ៖ យាយតាខាងម្ដាយគាត់កើតនោះគាត់កើតនៅ(ស្ដាប់អត់បាន)

ក៖ អូ៎!!ម្នាក់នោះភ្ញាក់ហើយណោះ គាត់បើកភ្នែកភ្លើមៗៗហើយ

ខ៖ យាយតានឹងតាកើតនៅស្រុកនឹងឯង

ក៖ អូ៎!!បាទយាយបាទ?

ខ៖ យាយរបស់ខ្ញុំនឹងនៅខាងត្រពាំងក្រឡឹងតែម្ដងនឹង

ក៖ អូ៎!!បាទៗៗយាយ ចុះសំរាប់យាយមករស់នៅនឹងយូរនៅយាយ?

ខ៖ ខ្ញុំអត់ទាន់ទេមីនេះនិយាយ

ក៖ ប៉ុន្តែយាយមករស់នៅភូមិនឹងយូរនៅយាយ?

ខ៖ នៅយូរដែរហើយ
ក៖ មកនៅបានប៉ុន្មានឆ្នាំហើយយាយ?

ខ៖ ដឹងអីអត់ដឹងផងនឹង

ក៖ យាយហាសមករស់នៅភូមិនឹងយូរនៅ?

ខ៖ យាយកើតមកតាំងពីជំនាន់ពលពត

ក៖ យាយកើតតែម្តងហោសយាយ?

ខ៖ ខ្ញុំកើតនៅនឹងចូលចិត្តជាងហើយ

ក៖ អូ៎!!ចឹងចូលចិត្តសិបឆ្នាំជាងហើយណាយាយ?

ខ៖ កើតនៅនឹងដីនៅនឹងតែម្តងនឹងអត់មានទៅណាទេ

ក៖ ចុះយាយមកកូនចៅណាដែរទៅរស់នៅក្រៅប្រទេសទេ?

ខ៖ អត់មានតែមួយនឹង

ក៖ បងប្អូនអីក៏អត់មានដែរហោស បងប្អូនជីដូនមួយអីក៏អត់មានទៅខាងថៃ វៀតណាម កូរ៉េទៅធ្វើការអី?

ខ៖ អត់មានទេជីដូនៗមួយអីនឹងនៅនឹង

ក៖ បងប្អូនរបស់បងនឹងមាននរណាគេទៅណាអីទេ ទៅក្រៅប្រទេសអីហាស?

ខ៖ អត់ទេ

ក៖ ចឹងអត់មានទេណាបង?

ខ៖ បងប្អូនខាងប្តីរបស់ខ្ញុំនឹងបានមាន

ក៖ គាត់ទៅណាដែរទៅបង?

ខ៖ បងប្អូនប្តីរបស់ខ្ញុំនឹងគាត់ចុះពីអាពតនឹងគាត់ទៅថៃ

ក៖ អូ៎!!គាត់នៅថៃហោសបង?

ខ៖ គាត់នៅថៃគាត់ទៅលេងម៉ែបានតែពីរដងនឹងគាត់បាត់រហូតនឹង

ក៖ អូ៎!!ចឹងហោសបង?

ខ៖ ហើយគាត់មានគ្រួសារនៅនឹង តែប្រពន្ធរបស់គាត់មិនអោយមកលេងទេ

ក៖ ជាជតិថៃហោសបង?

ខ៖ ចា៎!!នឹងហើយគាត់បួសធ្វើលោកតាំងពីគាត់អាយុតូចហោស
ដល់ពេលជំនាន់អាពតទៅក៏គេដេញ អោយគាត់ឡើងឡានហាស
ឡើងឡានទៅដឹកទៅថៃតែម្ដងនឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖ តែគាត់ធ្លាប់មកដែរតេមកពីកំលោះបានតែពីរដងទេបាត់រហូត

ក៖ អូ៎!!បាទបងបាទ?

ខ៖ អានឹងមានប្រពន្ធនឹងអានឹងបងប្អូនខាងប្ដីរបស់ខ្ញុំទេ
សំរាប់បងប្អូនខាងខ្ញុំនឹងអត់មានទេ អត់មាននរណាគេទៅថៃទៅអីទេកូន
យាយខ្ញុំនៅតែនឹករាល់ថ្ងៃយាយប្ដីរបស់ខ្ញុំនឹងហាស

ក៖ អូ៎!!គាត់នឹកកូនចៅគាត់ហោស?

ខ៖
ចា៎!!គាត់នឹកហើយគាត់អង្គុយបែរមុខទៅជើងនឹងថាម៉ោងប៉ុន្មានកូនមកអីញ្ចឹងនឹងហាស

ក៖ អូ៎!!បាទបងបាទ?

ខ៖ ពីព្រោះអីដឹងតែកូនវារស់ហើយនឹងហាស

ក៖ ចុះសំរាប់ស្វាមីរបស់យាយនឹងមានឈ្មោះអីគេដែរ?

ខ៖ អូ៎!!ពិបាកនិយាយណាស់ គាត់មានឈ្មោះត្រួក ឈ្មោះត្រួកតែម្ដងនឹង

ក៖ មានឈ្មោះត្រួក?

ខ៖ នឹងហើយឈ្មោះតាត្រួក

កៈ អូ៎!!ឈ្មោះតាត្រួកតែម្តងហោស?

ខៈ នឹងហើយពិបាកនិយាយពេក មានប៉ុន្មានទេ

កៈ អូ៎!! ចុះសំរាប់យាយការនៅថ្ងៃខែឆ្នាំណាដែរយាយមានចងចាំទេ?

ខៈ ការនឹងហេមិនចងចាំទេ ការតាំងពីជំនាន់សម្តេចឪនៅមិនទាន់

កៈ ប៉ុន្តែដូចជានៅឆ្នាំណាដែរទៅយាយ?

ខៈ ដូចជាសម្តេចឪមិនទាន់រត់ទេនៅខ្មែរក្រហម ចុះពលពតនឹងនៅឆ្នាំអីគេដែរចឹង?

កៈ ពលពតនឹងនៅឆ្នាំ1975-1979នឹង

ខៈ នៅឆ្នាំ1975-1979ហើយយាយឯងការហើយបានប៉ុន្មានខែបានប៉ុន្មានឆ្នាំដែរ
បានមួយឆ្នាំ

កៈ បានមួយឆ្នាំប៉ុន្តែកូនរបស់យាយនឹងកូនបងគេនឹងអាយុប៉ុន្មានដែរយាយ
កូនយាយកូនបងគេនឹងត្រូវជាម្តាយរបស់បងមែនទេ?

ខៈ នឹងហើយៗៗចឹង

កៈ ប៉ន្តែគាត់អាយុប៉ុន្មានដែរឥឡូវនឹង?

ខៈ នៅឆ្នាំម៉្សាញ់ប្រហែលជអាយុ50ឆ្នាំហើយនឹង

កៈ គាត់អាយុ50ឆ្នាំចឹងនៅពេលដែរយាយការហើយនឹងយាយនៅទំនេរពោះសិន
រឺមួយក៏យាយមានកូនតែម្តងនឹងយាយ?

ខៈ មានតែមួយនឹងទេ

កៈ ប៉ុន្តែនៅពេលដែរយាយការហើយនឹងយាយមានកូនតែម្តងនឹង រឺក៏នៅទំនេរពោះសិន?

ខៈ
ចង់និយាយថាយាយឯងការហើយនឹងបានកូនភ្លាមនឹងរឺក៏ទំនេរពោះបានរយះពេលប៉ុន្មាន
ខែអី ប៉ុន្មានឆ្នាំដែរអីចឹងហាស បាន5ខែ

កៈ អូ៎!!ចឹងបានយាយចាប់ផ្តើមមានកូន?

ខ៖ នឹងហើយ

ក៖ អូ៎!!ចឹងមានន័យថាយាយការអស់50ឆ្នាំជាងហើយណាបង?

ខ៖ នឹងហើយចឹង

ក៖ ប្រហែលជាងខ្ទង់ជាង50ឆ្នាំហើយណាបង?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះនៅពេលដែរបានរៀបអាពាហ៍ពិពាហ៍នឹងគិតថាយាយជាអ្នករៀបចំដោយចិត្តឯងរឺមួយឪពុកម្ដាយជាអ្នករៀបចំអោយដែរយាយ?

ខ៖ ខ្ញុំអត់ដែរស្គាល់ប្ដីរបស់ខ្ញុំទេនឹង

ក៖ អូ៎!!ចឹងយាយមិនដែរស្គាល់គ្នាទេណាយាយ?

ខ៖ ម៉ែឪនឹងជាអ្នករកអោយតែម្ដងនឹង

ក៖ អូ៎!!ចឹងហោសយាយ?

ខ៖ នឹងហើយអោយម៉ែរកអោយមែនតើ!!

ក៖ ប៉ុន្តែនៅពេលដែរតាចូលស្ដីដណ្ដឹងយាយនឹង តាមានជាជំនូនជូនទៅយាយដែរទេជាថ្លៃទឹកដោះហាស?

ខ៖ មានជូន

ក៖ ពេលណុងតាជូនអីគេដែរទៅយាយ?

ខ៖ ជូនមាសនឹងហាស

ក៖ ប៉ុន្តែពេលណុងជូនមាសប៉ុន្មានជីទៅ?

ខ៖ បានមាស5ជី

ក៖ អូ៎!!ប៉ុន្តែពេលណុងមាសថោកលុយថ្លៃហីយាយ?

ខ៖ នឹងហើយជំនាន់ណុងមួយជី កាលពីជំនាន់ណុងខ្ញុំការមួយជី300

កៈ បាទ!! ចុះពេលណុងយាយបានមាស5ជីនឹងយាយយកទៅធ្វើអីគេដែរទៅ?

ខៈ ទុញាក់នឹងហាស

កៈ អូ៎!!និយាយលេង ចឹងសំរាប់យាយធ្លាប់បានចូលរៀនទេយាយ?

ខៈ អត់ដែរ

កៈ អត់ដែរបានរៀនសោះតែម្តងនឹងហោសយាយ?

ខៈ អត់ដែរបានរៀនទេ

កៈ ប៉ុន្តែយាយមានចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរដែរទេយាយ?

ខៈ អត់ទេ អទ់មានដែរស្គាល់ទេ

កៈ អត់ចេះទេហោសយាយ កាលពីជំនាន់ណុងអត់អោយរៀនទេហោសយាយ?

ខៈ គេមិនអោយរៀនតែម្តងនឹង មិនមែនមិនអោយទេគាត់អត់ចេះតែម្តងនឹង បើតារបស់ខ្ញុំនឹងគាត់រៀន ទៅសុទ្ធតែដល់ភ្នំពេញអីនឹងតាំងពីកង់គួកមកនឹង ខ្ញុំរៀនអត់ចូល

កៈ តាំងពីជំនាន់កង់គួកនឹងហីបង?

ខៈ នឹងហើយតារបស់ខ្ញុំនឹងកំពូលហើយ

កៈ ប៉ុន្តែយាយធ្លាប់ចូលរៀនប៉ុន្តែរៀនអត់ចូលហី?

ខៈ អត់អត់ចូលទេ

កៈ អូ៎!!បាទ ប៉ុន្តែយាយមានចេះភាសាបារាំងទេយាយ?

ខៈ អត់ទេនឹង

កៈ ភាសាអីក៏អត់ចេះដែរហោសយាយ?

ខៈ អត់ទេ

កៈ ប៉ុន្តែចឹងយាយចេះតែភាសាខ្មែរទេ?

ខៈ ចេះតែខ្មែរនឹងហាស

កៈ
ចុះយាយគិតថាកាលពីក្មេងនឹងយាយធ្លាប់មានមិត្តភក្តិដៃរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាដែរទេ?

ខៈ មានមិត្តភក្តិស្និទ្ធិស្នាលអីអត់ ឧទាហរណ៍ថាយាយកង
យាយស៊ឹមអីដៃរស្និទ្ធិស្នាលជាមួយយាយឯង អីអត់អ្នកនៅក្នុងភូមិនឹងហាស
មានដៃរស្និទ្ធិស្នាលនៅក្នុងភូមិនឹង

កៈ អូ!!ប៉ុន្តែពយកគាត់មានឈ្មោះអីគេខ្លះដែរទៅយាយ?

ខៈ មានឈ្មោះយាយកង យាយពូក

កៈ ឈ្មោះយាយពូក?

ខៈ នឹងហើយ

កៈ
ប៉ុន្តែធ្លាប់មានអនុស្សាវរីយ៍អីកាលពីនៅក្មេងៗៗនឹងធ្លាប់បានលេងអីជាមួយក្នាដែរទេយាយរឺមួយក៏ទៅស្រែអីចឹងហាស

ខៈ នឹងហើយធ្លាប់ជាមួយគ្នានឹង3នាក់នឹងលេងជាមួយគ្នានឹង

កៈ លេងអីគេដែរយាយ?

ខៈ
លេងនឹងចេះតែលេងទៅលេងនឹងយើងអត់មានគិតអីទេចេះតែលេងទៅបាយឡឹកបាយឡទៅ គិតតែការគ្នាការឯងចឹងទៅ

កៈ អូ!!បាទយាយបាទ?

ខៈ កាលនៅក្មេងៗៗជំនាន់ណុងការគ្នាឯងៗៗចឹងទៅ

កៈ ការស្រីៗៗគ្នាឯងចឹងហោសយាយ?

ខៈ ការចឹងឯងនឹង

កៈ ម្នាក់ធ្វើប្រុស ហើយនឹងម្នាក់ទៀតធ្វើស្រីហោសយាយ?

ខ៖  នឹងហើយចឹងការឈើការព្រៃទៅនាំគ្នាចេញមកពាក់

ក៖  ប៉ុន្តែធ្លាប់ទៅស្រែអីជាមួយគ្នាដែរតើហ៏យាយ?

ខ៖  ធ្លាប់ទៅស្រែជាមួយគ្នា ទៅចឹងទៅមាន3នាក់

ក៖  បាទយាយ ចុះយាយគិតថាយាយតាំងពីក្មេងរហូតមកដល់ពេលនេះយាយធ្លាប់បានធ្វើការងារអីគេខ្លះដែរទៅយាយ?

ខ៖  ពីក្មេងនឹងហោស ខ្ញុំភ្ជួរ

ក៖  បាទយាយភ្ជួររាស់ណាយាយ?

ខ៖  នឹងហើយភ្ជួររាស់នឹង

ក៖  អូ៎!!ចឹងមានន័យថាយាយធ្លាប់ទៅធ្វើការងារនៅស្រែដែរ?

ខ៖  នឹងហើយធ្វើ

ក៖  ប៉ុន្តែយាយធ្វើការងារនៅស្រែនឹងយាយទៅតែភ្ជួររាស់នឹង រឺមួយក៏យាយមានធ្វើអីផ្សេងទៀតយាយ?

ខ៖  មានអីផ្សេងទៀតចឹងទៅ មករៀបចំដាំបាយដាំទឹកអីអោយហូបចឹងទៅ

ក៖  អូ៎!!ចឹងហោសយាយ?

ខ៖  មកពីភ្ជួរចឹងទៅ ដាំបាយដាំទឹកហូបចឹងទៅដើបទៅភ្ជួរទៀតចឹងទៅ

ក៖  បាទយាយ ចុះយាយគិតថាយាយមានធ្លាប់បើកមុខរបរអាជីវកម្មអីផ្សេងទេយាយ?

ខ៖  អត់ទេនឹង

ក៖  ចឹងអត់ដែរទេណាយាយ?

ខ៖  ធ្លាប់ដែរធ្លាប់តែបើកតិចតួច

ក៖  មានលក់អីគេដែរទៅយាយ?

ខ៖  លក់តិចតួចលក់ស្ករគ្រាប់ លក់បារី លក់ទឹកចឹងទៅបារី ស្ករគ្រាប់ប៉េងប៉ោងអោយក្មេងលេងចឹងទៅ ដល់ពេលដែរចាស់ចឹងទៅលក់មិនដូចក្មេងទេនោះទៅលក់ខាងនោះនឹង

ក៖  បាទបង ចុះយាយគិតថាជីវិតរបស់យាយនឹងមានការផ្លាស់ប្តូរអីដែរតាំងពីក្មេងរហូតមកដល់ពេល

នេះហោសយាយ?

ខ៖  ផ្លាស់ដែរតើ!!

ក៖  មានការផ្លាស់ប្តូរអីគេខ្លះដែរទៅបង?

ខ៖  ដូចថាមានការផ្លាស់ប្តូរដូចថាការរកស៊ីអីចឹងទៅណាស់

ក៖  បាទយាយបាទនឹង?

ខ៖  ខែវស្សាគាត់ធ្វើស្រែ ខែប្រាំងគាត់ដើរកាច់ស្លឹកឈើលក់ចឹងទៅ

ក៖  បាទបងបាទ?

ខ៖  ខ្ញុំនៅតូចនឹងខ្ញុំចងចាំដែរ

ក៖  អូ!!បាទបងបាទនឹង?

ខ៖  គាត់កាចស្លឹកឈើហើយនឹង គាត់ទិញម្នាស់គេយកមកលក់នឹង

ក៖  កាត់ទៅទិញម្នាស់យកមកលក់ណាបង?

ខ៖  នឹងហើយកាត់ទិញយកមកទូលលក់កាច់ផ្តៅកាច់អីយកទៅលក់នៅផ្សារដល់ពេលដែរមកវិញចឹងទៅទិញនេះទិញនោះចឹងហាស

ក៖  កាច់ផ្តៅហោសយាយ?

ខ៖  នឹងហើយយកទៅលក់នឹង ស្លឹកស្តៅនឹង

ក៖  អូ!!ស្លឹកស្តៅហោសខ្ញុំស្មានតែផ្តៅ?

ខ៖ យកទៅលក់នៅផ្សារចឹងទៅដកម្អមដកអីចឹងទៅ

ក៖ បាទយាយបាទ?

ខ៖ ដកម្អមដកអី ដើរទូលទៅណាស់

ក៖ បាទយាយបាទ?

ខ៖ យាយមិនទំនេរទេដល់ពេលចាស់ចឹងខ្ញុំធ្វើអីកើត
កាលនៅយាយក្មេងយាយមានកំលាំងហាសណាស់

ក៖ ប៉ុន្តែឥឡូវនឹងសុខភាពរបស់យាយនឹងយ៉ាងម៉េចដែរទៅ?

ខ៖ អើរថ្ងៃណាវាគ្រុនក៏គ្រុនទៅ ថ្ងៃណាវាអត់អីក៏អត់អីទៅនឹង

ក៖ អូ!!បាទយាយបាទ?

ខ៖ ចុះយើងចាស់ហើយនឹង

ក៖ ចុះសំរាប់យាយនឹងគិតថាយាយចូលចិត្តពិសារម្ហូបអីគេដែរយាយ?

ខ៖ ពិសារអីគេ

ក៖ យាយចូលចិត្តពិសារម្ហូបអីគេដែរយាយ?

ខ៖ ចូលចិត្តហូបម្ហូបអីគេដែរ ញ៉ាំរាល់ថ្ងៃនឹងហាសមានតែគ្រៀមក្រោសនឹង
មានត្រីងៀតទៅអីទៅ

ក៖ នឹងតាហោសបង?

ខ៖ ប្អូនថ្លៃគាត់នឹងប្អូនថ្លៃខ្ញុំទេ ប្តីយាយប្អូនគាត់

ក៖ អូ!!ប្តីយាយប្អូនរបស់យាយហោស?

ខ៖ ចា៎!!នឹងហើយចឹង

ក៖ អូ!!បាទតិចទៀតនឹងខ្ញុំជួបគាត់ម្តងនឹង គាត់និយាយដូចយាយដែរ?

ខ៖ អូ!!បើនិយាយដូចគ្នានឹងហាស

កៈ ចុះយាយគិតថាយាយចេះច្រៀងដែរទេ?

ខៈ អត់ចេះទេ

កៈ ប៉ុន្តែពីមុននឹងយាយមានធ្លាប់បានរៀនច្រៀងរៀនអីទេ?

ខៈ អត់ចេះទេចេះតែ

កៈ បំពេកូនចៅ?

ខៈ ចេះតែបុះពេកូនចៅនឹងលេងជាមួយចៅចឹងទៅ

កៈ ឥឡូវនឹងយាយសាកដាក់បំពេចៅមួយបទបានទេ?

ខៈ អត់ចេះទេខ្ញុំភ្លេចអស់ហើយនឹង

កៈ ខ្ញុំនិយាយលេងទេយាយ?

ខៈ ខ្ញុំដាក់ដៃកាច់ផ្កានឹងហោស

កៈ សាកដាក់មួយបទអោយចៅថ្ងូរ ខ្ញុំនិយាយលេងទេយាយ?

ខៈ អត់ទេអត់ចេះទេ

កៈ ចុះយាយគិតថាមាននរណាម្នាក់បងប្អូននៅក្នុងក្រុមគ្រួសាររបស់យាយនឹងចេះលេងឧបករណ៍ភ្លេងដែរទេយាយ?

ខៈ អត់អត់មានទេ

កៈ បងប្អូនរបស់បងអីមាននរណាគេចេះលេងទេ?

ខៈ រឿងលេងភ្លេងអីនឹងអត់មានទេ

កៈ លក្ខណះភ្លេងបុរាណ ភ្លេងខ្មែរ ភ្លេងសៀម ភ្លេងពិនពាតអីក៏អត់មានដែរ?

ខៈ អត់មានទេ

កៈ ចឹងអត់មានដែរហោសយាយ?

ខ៖ អូ៎!!បងជីដូនមួយនឹងមាន បងជីដូនមួយនឹងបានមានខឿន
ហោសលេងភ្លេងការនឹងហាស

ក៖ អូ៎!!លេងភ្លេងការហោសបង?

ខ៖ អូ៎!!នឹងជីដូនមួយនឹងលេងភ្លេងការ ប្អូនជីដូនមួយបង្កើតនឹង

ក៖ អូ៎!!បាទ
ចុះផ្ទះរបស់យាយនឹងមានលក្ខណះបែបម៉េចដែរតាំងពីក្មេងរហូតមកដល់ពេលនេះចឹង
ពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដែរចឹងហាសយាយ?

ខ៖ កាលពីក្មេងនឹងឪរបស់ខ្ញុំនឹងគាត់នៅផ្ទះពីរខ្នងដែរ មានពីរខ្នងជើងសសរស៊ីម៉ង

ក៖ អូ៎!!ជើងសសរស៊ីម៉ង់នឹង អូ៎!!បាទយាយបាទ?

ខ៖ នឹងហើយចឹង

ក៖ ចុះនរណាគេជាអ្នកសាងសងផ្ទះនឹងដែរយាយ?

ខ៖ ឪពុករបស់ខ្ញុំនឹងហាស

ក៖ ប៉ុន្តែកាត់មានចេះធ្វើផ្ទះទេនឹង?

ខ៖ អត់ទេ អត់ចេះទេនឹង

ក៖ ប៉ុន្តែប្តីរបស់យាយចេះធ្វើផ្ទះ?

ខ៖ ប្តីរបស់ខ្ញុំនឹងចេះតែបើកឡាន

ក៖ ចេះតែបើកឡាន?

ខ៖ អត់ចេះធ្វើស្រែទេ ចេះតែបើកឡាននឹងទេ

ក៖ ចុះយាយគិតថាជំនាញអីដែរយាយគិតថាយាយចេះស្ទាត់ជំនាញតែម្តងនឹងហាស
នៅក្នុងជីវិតរបស់យាយហាស?

ខ៖ ជំនាញនឹងវាចេះតែច្រើនហើយនឹងជំនាន់ខ្ញុំនឹងត្បាញក្រម៉ានឹងយើងចេះ

ក៖ អូ៎!!យាយចេះត្បាញក្រម៉ាទៀតហោសយាយ?

ខ៖ ចេះមួយថ្ងៃបានក្រម៉ា3នឹង

ក៖ អូ៎!!បាទយាយ ចុះយាយគិតថាឪពុកម្ដាយរបស់យាយមានធ្លាប់បង្រៀនពីជំនាញអីទៅយាយដែរទេ ដូចលក្ខណះថាវេញវល្លិ៍ ធ្វើផ្ដៅ កូរស្ករត្នោត ធ្វើកន្ទេលអញ្ចឹតអីចឹងហាស?

ខ៖ អត់ទេនឹង

ក៖ ចឹងយាយចេះតែត្បាញក្រម៉ាទេហោសយាយ?

ខ៖ នឹងហើយចេះតែរត្បាញក្រម៉ា ត្បាញកន្ត្រក់ពីផាងត្នោតនឹងចេះ

ក៖ បាទយាយ ចុះយាយគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះ គិតថាជីវិតរបស់យាយធ្លាប់ជួបទុកលំបាកអីគេខ្លះនៅក្នុងជីវិតចឹងហាសយាយ ពីក្មេងមានបញ្ហាអីដល់ ឥឡូវនឹងចឹងហាសយាយ?

ខ៖ ពីក្មេងនឹងអត់មានពិបាកទេ

ក៖ ម៉េចចឹងយាយ?

ខ៖ ពិបាកតែយើងទៅស្រុកគេណោះនឹងពិបាកគ្មានទាំងពិបាកទេ

ក៖ ចុះយាយកាលពីជំនាន់យាគកុងនឹងយាយបានស្គាល់យាគកុងទេ ពួកវៀតណាមចូលស្រុកយើងហោសយាយ?

ខ៖ ខ្ញុំស្គាល់តើ!!

ក៖ ប៉ុន្តែពេលណុងវាមានធ្វើយាយនឹងក្រុមគ្រួសារយាយអីទេយាយ?

ខ៖ អត់ទេនឹង

ក៖ ចឹងអត់ទេណយាយ ចុះជំនាន់លុនណុលវិញយាយ?

ខ៖ ជំនាន់លុនណុលនឹងក៏អត់ដែរដល់ណែ

ក៖ ជំនាន់ពលពតវិញយាយ?

ខ៖ ដល់ជំនាន់ពលពតនឹងបានប្ដីរបស់ខ្ញុំនឹងគេធ្វើបាប

កៈ ប៉ុន្តែយាយពេលណុងត្រូវជំលាសទៅណាទៅយាយ?

ខៈ ជំលាសទៅហ្វូសស្លាបលែងហោសចៅ

កៈ នៅណាវិញយាយ?

ខៈ នៅស្លាបលែងហោស

កៈ អូ៎!!នៅស្លាបលែងហោសយាយ?

ខៈ នឹងហើយ

កៈ ពេលណុងគេអោយយាយទៅធ្វើអីគេដែរទៅយាយនៅណុង?

ខៈ ទៅនឹងយាយនឹងគេមិនអោយធ្វើអីទេនឹង អោយធ្វើយតែសេដ្ឋកិច្ច

កៈ ធ្វើអីគេវិញយាយ?

ខៈ សេដ្ឋកិច្ចដាំស្លអោយគេ ចុងភៅ

កៈ អូ៎!!ចុងភៅហោសយាយ ខ្ញុំស្មានតែសេដ្ឋកិច្ច?

ខៈ ហាសខាងណុងមិនគេហៅសេដ្ឋកិច្ច

កៈ អូ៎!!ចឹងហោសយាយ?

ខៈ នឹងហើយនៅជំនាន់អាពតនឹងគេហៅសេដ្ឋកិច្ច

កៈ អូ៎!!បាទយាយ ចឹងយើងធ្វើតែចុងភៅទេណាយាយ?

ខៈ រហូតធ្វើចុងភៅតែយើងខ្មាំងហោស

កៈ ប៉ុន្តែចុងភៅនឹងហូបឆ្អែតរហូតណាយាយ?

ខៈ អើរនឹងហើយចុងភៅហូបឆ្អែតហើយនឹងសេដ្ឋកិច្ចអត់អីទេ

កៈ បាទយាយ ចុះពេលណុងយាយទៅម្នាក់ឯងរឺមួយយាយទៅជាគ្រួសារដែរយាយ?

ខៈ ទៅទាំងគ្រួសារបងប្អូនឪរបស់ខ្ញុំនឹងម៉ែរបស់ខ្ញុំនឹងទៅទាំងអស់នឹង

កៈ អូ៎!!គេជំលាសអោយទៅទាំងគ្រួសារតែម្តងនឹងហោសយាយ?

ខ៖  នឹងហើយអត់ទេទៅទាំងគ្រួសារនឹងបានតែយាយហើយនឹងតានឹង
បើម៉ែរបស់ខ្ញុំនឹងបែកទៅជើងចេះ នឹងហាសខាងតឹងក្រូច

ក៖  អូ៎!!ចឹងហោសយាយ?

ខ៖  បែកពីខ្ញុំហើយនឹងប្អូនរបស់គាត់នឹងបែកទៅជាមួយម៉ែរបស់ខ្ញុំនឹង

ក៖  អូ៎!!ចឹងហោស?

ខ៖  នឹងហើយម្ដាយមីងនឹងអោយទៅចេះ

ក៖  មិនមែនទៅជុំគ្នាផងហោសបង?

ខ៖  អត់បានជុំគ្នាដែរនឹងម៉ែគាត់

ក៖  ហើយនឹងគាត់ចឹងទៅ?

ខ៖  ចា៎!!បែកកូនចឹងដែរ

ក៖  អូ៎!!បាទយាយបាទ?

ខ៖  កូននៅជើងទៅ ម៉ែនៅនោះចឹងទៅ

ក៖  ប៉ុន្តែនៅ3ឆ្នាំ 8ខែ 20ថ្ងៃនឹងយាយនៅតែធ្វើចុងភៅនឹងរហូត?

ខ៖  នឹងហើយ

ក៖  នៅធ្វើកន្លែងសេដ្ឋកិច្ចនឹងរហូតនឹង?

ខ៖  នៅកន្លែងសេដ្ឋកិច្ចនៅស្លដាំអោយគេហូបនឹង

ក៖  រហូតទាល់តែដាច់ពលពតណាយាយ?

ខ៖  ដាច់ពលពតមកនឹងបានយើងចុះមកនឹងហាស

ក៖  បាទយាយបាទនឹង?

ខ៖  ចុះមកបានយើងអត់ហើយនឹងអត់ហើយ

ក៖  អូ៎!!បាទយាយបាទ?

ខ៖ ទៅរកបាយហូបនៅចំដៅដូចយើងរាល់ថ្ងៃចឹងអត់ពិបាកទេ

ក៖ អូ៎!!ពេលនឹងពេលដែរដាច់ពលពតនឹងយាយត្រូវលំបាកត្រូវរកលុយរកអី ដោយសារតែពេលណុងគេ
ចាប់ផ្ដើមចាយលុយចឹងទៅយាយចាប់ផ្ដើមរកលុយចាយរកអីណាយាយ?

ខ៖ បានលុយមកពីណាមកណាជំនាន់ណុងយើងចុះមកនឹងអត់បានលុយទេ

ក៖ លឺថាយើងធ្វើស្រែដូរយកអង្ករយកអីហីយាយ?

ខ៖ នឹងហើយប្ដូរអង្ករនឹងយកម្ហូបយកអីអោយចឹងទៅ

ក៖ បាទយាយបាទនឹង រហូតដល់ឆ្នាំណាគេចាប់ផ្ដើមចាយលុយស្រួលបួលហាសយាយ ដូចជាឆ្នាំប៉ែតជាងប៉ុន្មានយាយ?

ខ៖ ទេនៅឆ្នាំប៉ែតប៉ុន្មានទេបានមានលុយចាយនឹងភ្លេចដែរនឹងចៅអើយយូរដែរហើយនឹង

ក៖ អូ៎!!ចឹងហោសយាយ?

ខ៖ ម៉ាយាយឥឡូវនឹងចាស់ហើយកាលនៅក្មេងហាសត្នោតក៏ខ្ញុំឡើងដែរ

ក៖ អូ៎!!យាយឡើងត្នោតទៀតហោសយាយ?

ខ៖ ឡើងត្នោតកាប់ស្លឹកមួយថ្ងៃពីរដើមទៅមួយថ្ងៃបីដើមនឹង

ក៖ អូ៎!!ឡូយជាងខ្ញុំដែរ?

ខ៖ ចុះបើប្ដីគាត់ស្លាប់ហើយម៉ែរបស់ខ្ញុំនឹងទៅមិនរួចទេយាយតាក៏គាត់ចាស់

ក៖ អូ៎!!ចឹងមានតែយាយទេណាយាយ?

ខ៖ នឹងហើយភ្លួរាស់អីនឹង

ក៖ អូ៎!!ចឹងយាយខ្លាំងហើយណាយាយ?

ខ៖ ភ្លួរាស់ ឡើងត្នោត

ក៖ ចឹងបានចៅៗស្រលាញ់យាយនឹង?

ខ៖ អូ៎!!អត់រវល់ទេ

កៈ អូ៎!!អត់រវល់ផងយាយ?

ខៈ អត់រវល់គ្រង់ថាចៅអត់ស្រលាញ់ទេ
មកពីណាពីណរឹមកទិញនំចំណីអោយយាយហូបរហូតនឹង

កៈ អូ៎!!បាទយាយបាទ?

ខៈ អាមួយនៅភ្នំពេញណោះចៅមួយណោះនឹង មានចៅតែពីរនាក់នឹងទេ

កៈ បាទយាយ ចុះយាយគិតថាយាយឆ្លងកាត់ឧបសគ្គនឹងដោយរបៀបណាដែរយាយ?

ខៈ អាជំនាន់យើងធ្វើនោះ

កៈ
ចង់និយាយថាយាយតាំងពីក្មេងរហូតមកដល់ពេលនេះយាយឆ្លងកាត់ឧបសគ្គដោយរបៀប
ណាដែរ យាយជំនះចឹងហាសយាយ?

ខៈ ឥឡូវនឹងយើងសប្បាយហើយនឹង

កៈ បាទយាយបាទនឹង?

ខៈ
ចុះយាយឯងមិនប្រាប់គាត់មកពីពលពតមកនឹងនៅឆ្នាំ1979នឹងពេញលំបាករបៀបមម៉េច
ដែរ អូលំបាកនិយាយអីមិនចេញទេ តាំងពីឆ្នាំ1979នឹងលំបាកយ៉ាងម៉េចទៀត
នឹងហើយចុះមកលំបាកចឹងធ្វើ បបរលក់ ធ្វើស្លឹកឈើ ស្លឹកព្រៃចឹងទៅ

កៈ អូខេមួយនឹងយាយ?

ខៈ បានរួចមួយឆ្នាំទៅបានយើងបានធ្វើស្រែខ្លួនឯងខ្លះចឹងទៅ បានបានបាយហូបចឹងទៅ

កៈ អូ៎!!នឹងហោសយាយ?

ខៈ ធ្វើស្រែនឹងក៏ធ្វើរួមដែរនឹង

កៈ ធ្វើរួមហើយចែកគេណយាយ?

ខៈ ហើយចែកមិនដែរឆ្អែតទេ មានអាចែកស្រូវមួយកំប៉ុងក៏ឃើញដែរនឹង

កៈ  បាទៗៗយាយ?

ខៈ  វាច្រើនដល់បានបីបួនដប់កំប៉ុងចឹងទៅ វាមុននឹងទៀតហោសបានច្រើនទៀតហោស

កៈ  អូ៎!!ចឹងហោសយាយ?

ខៈ  ចុះខ្ញុំមានកូនតែមួយនឹងចឹងចៃកបានតិច

កៈ  អូ៎!!ចៃកបានតិចនឹង?

ខៈ  បានតិចនឹងហាស

កៈ
ចុះយាយគិតថាពេលណាដែរយាយគិតថាពេលដែរសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់យាយតែ ម្ដងនឹងហើយយាយពេលណាដែរយាយ?

ខៈ  ពេលឥឡូវនឹងហាស

កៈ  អូ៎!!ឥឡូវនឹងហោសយាយ?

ខៈ  សប្បាយស្អីក៏ឃើញភ្លើងឆេះណៃមានអីគ្រប់មុខនឹងទូរទស្សន៍អីគនឹង
បើកមើលសប្បាយភ្នែកមើលពេលចាស់តែម្ដងនឹង

កៈ  អូ៎!!បាទយាយបាទ?

ខៈ  នឹងហើយសម័យគេហ៊ុនសែនឥឡូវនឹងហោស

កៈ  អូ៎!!បាទយាយបាទ?

ខៈ  សប្បាយណាស់នឹង

កៈ
ចុះយាយគិតថាកាលពីក្មេងនឹងយាយធ្លាប់មានគោលបំណងថាពេលដែរធំឡើងនឹងយាយចង់ធ្វើជាស្អីដែរទេយាយ?

ខៈ  កាលពីនៅក្មេងនឹង

កៈ  យាយមានធ្លាប់ស្រម៉ៃអីដែរទេ?

ខ៖  យាយស្រម៉ៃថាចង់ក្លាយជាតារាចំរៀងអត់ទេ អត់ដែរទេចៅ

ក៖  ចុះយាយមានធ្លាប់គិតថាយាយចង់ធ្វើជាគ្រូបង្រៀន រឺមួយក៏គ្រូពេទ្យអីទេយាយ?

ខ៖  អត់ទេ

ក៖  អត់មានទេហោសយាយ ចុះយាយធ្លាប់គិតអីចឹង?

ខ៖  គិតថាការងារអីធ្វើចឹងទៅ ចុះបើគាត់រើនអត់ចូលផងនឹង

ក៖  អូ៎!!បាទយាយបាទ?

ខ៖  បានតែត្បាញក្រម៉ាត្បាញអីចឹងទៅ រវៃអីចឹងទៅ

ក៖  អូ៎!!បាទយាយបាទ ចុះបើសិនជាចង់អោយយាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗ នឹងតើយាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរយាយ?

ខ៖  ផ្តែផ្តាំយ៉ាងមេចទៅ

ក៖  ចង់និយាយថាយាយចង់ផ្តែផ្តាំអោយគាត់ខំប្រឹងរៀន ដើម្បីអោយគាត់មានអនាគត់ល្អចឹងហាសយាយ?

ខ៖  អូ៎ៗៗ!!ផ្តែផ្តាំដែរតើចៅ ផ្តាំចៅៗៗទូតនឹងរៀនថាចៅអើយខំរៀនអោយចេះ ហើយកុំអោយដៃខូច អោយចិត្តត្រង់ដូចអាចៅទៅរៀននៅភ្នំពេញចឹងហាស មកម្តងនឹងៗៗខ្ញុំត្រដរចៅវាល់តែគេស្រលាញ់ យើងនឹងហាស អោយចេះរៀន

ក៖  បាទយាយបាទ?

ខ៖  រៀនគឺគិតតែរៀនពេលធ្វើការនឹងគិតតែធ្វើការនឹង

ក៖  បាទយាយចុះបើសិនជាចង់អោយកូនចៅជៀសវៀងវិញ តើយាយគិតថាចង់អោយកូនចៅនឹងជៀសវៀងនៅអំពើអីគេខ្លះដែរទៅ មើលទៅអត់ល្អនៅក្នុងសង្គមចឹងហាសយាយ?

ខ៖  ថ្នាំញៀន ចង់អោយតែចៅជៀសវៀងនៅផ្លូវអាក្រក់ៗៗហាស អត់អោយ យាយចង់អោយជៀសអត់ ចង់អោយជៀស

ក៖  ចុះជៀសពីអីគេដែរយាយ?

ខ៖ មានផ្លូវអីគេខ្លះដែរចឹង អំពើអីគេខ្លះដែរចឹងហាសផ្លូវអស់នឹងហាស លួចប្លន់មួយមុខ

ក៖ មានគ្រឿងញៀន?

ខ៖ មានគ្រឿងញៀន

ក៖ មានល្បែងស៊ីសងនឹង?

ខ៖ មានល្បែងស៊ីសងនឹង អោយជិះម៉ូតូកុំអោយលឿន

ក៖ ហូបស្រានឹងកុំអោយបើកបរអីចឹងហោសយាយ?

ខ៖ នឹងហើយកុំអោយបើកបរអីចឹង បើយើងជិះនៅអមភូមិអមអីនឹងកុំអោយលឿនណាចៅ

ក៖ បាទយាយបាទ?

ខ៖ ជិះយើងធម្មតាចឹងទៅប្រជាជននឹងគេថាហេអានេះកូននរណាគេនឹងហោស

ក៖ ជិះអីលឿននឹងហោសយាយ?

ខ៖ ជិះអីក៏សុវត្ថភាពអីក៏ស្រួលម្លេះខ្ញុំប្រដៅចៅរបស់ខ្ញុំចឹងណាស់

ក៖ បាទយាយបាទ ចឹងមានអីដែរយាយចង់ផ្ដែផ្ដាំទៀតអត់យាយ?

ខ៖ មិនដឹងថាផ្ដែផ្ដាំថាម៉េចទៅទៀតហោស

ក៖ ចឹងអត់ទេហោសយាយ?

ខ៖
ចង់ផ្ដែផ្ដាំថាកូនចៅជំនាន់ក្រោយមិនថាកូនអ្នកណាៗៗទេនឹងជៀសវៀងអានឹងអោយវាសុខសប្បាយ ទាំងអស់គ្នានឹងហាស រឿងប្លន់ រឿងគ្រឿងញៀនអីចឹងហាស រឿងល្បែងអីនឹងល្បែងស៊ីសង

ក៖ អូ៎!!បាទយាយបាទនឹង?

ខ៖ ល្បែងស៊ីសងនឹងអូខ្ញុំស្អប់ណាស់ខ្ញុំសូមទោស អត់មានទេ
មានប៉ូលីសចាប់ច្រើនណាស់ ចឹងមួយពូជ នឹងអត់មានទេ

ក៖ បាទយាយបាទអត់មាននរណាគេចេះទេហោសយាយ?

ខ៖ អត់ទេនឹង

ក៖ អ៎ូ!!បាទយាយបាទ?

ខ៖ ទៅថៃនឹងក៏អត់មានអ្នកទៅដែរចៅ

ក៖ អ៎ូ!!ចឹងបាទយាយបាទ?

ខ៖ កូនទៅថៃនឹងក៏អត់មាននរណាគេទៅដែរនឹងបើកូនចៅរបស់ខ្ញុំនឹង

ក៖ បាទយាយបាទ?

ខ៖ អត់មាននរណាគេចេះទេ

ក៖ អ៎ូ!!ចឹងហោសយាយ?

ខ៖ អត់មានទេអារឿងតិចតួចនឹងរឿងថ្នាំញៀនថ្នាំអីនឹងអត់មានទេចៅ

ក៖ បាទយាយបាទចឹង?

ខ៖ ខ្ញុំស្អប់ណាស់រឿងចឹង

ក៖
បាទយាយចឹងជាចុងក្រោយនឹងខ្ញុំអរគុណច្រើនយាយដែរបានអោយខ្ញុំបានពិភាក្សាដែរបានទាក់ទង ពីប្រវត្តិរបស់យាយ

ខ៖ សុខសប្បាយចៅទាំងអស់គ្នានឹងណា

ក៖
ចឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដើម្បីតំកល់ទុកអោយយាយ
ដើម្បីអោយកូនចៅជំនានក្រោយៗរបស់យាយដែរយាយបានរៀបរាប់ជាមួយខ្ញុំមិញចឹងហាសយាយ?

ខ៖ ចា៎!!នឹងហើយចឹង

ក៖ ចឹងអោយពួកគាត់បានស្តាប់នឹងធ្វើតាមគំរូរបស់យាយ?

ខ៖ អោយកូនចៅគេមើលឃើញហោស

ក៖ បាទយាយបាទចឹងអរគុណច្រើនណាស់យាយ៕៕៕